ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៧៣

ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០០

**សាលដីកា**

លេខ : ៤២

ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ដោយមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ជាប្រធាន

២- លោក ប៉ែន សារឿន ជាចៅក្រម

៣- លោក គង់ ភិរុន ជាចៅក្រម

៤- លោក ស៊ិន ឌឹម ជាចៅក្រម

៥- លោក ជីវ កេង ជាចៅក្រម

៦- លោក ឈឹម ស៊ីផល ជាចៅក្រម

៧- លោក សោម សិរីវឌ្ឍ ជាចៅក្រម

៨- លោក ប្រាក់ គឹមសាន ជាចៅក្រម

៩- លោក យស់ សូខឿន ជាចៅក្រម

ក្រឡាបញ្ជី

លោក ស៊ិន ភារៈ

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

លោក ប៉ែន ស៊ុន ជាចៅក្រមរបាយការណ៍ "អវត្តមាន"

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៣៨"ក"ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១០៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍វេាង :

ដើមចោទឈ្មោះ ណោប សាម៉ាន់ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៥១ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីម្ចាស់ភោជនីយដ្ឋានសេរីភាពថ្មី ទីលំនៅភូមិលេខ៥ ឃុំ.ស្រុក.ខេត្តស្វាយរៀង ឪពុកឈ្មោះ ណោប ប៊ុន "ស្លាប់" ម្តាយឈ្មោះ គួច សេក "ស្លាប់" ប្រពន្ធឈ្មោះ សោម គីម ។

ចុងចម្លើយឈ្មោះ អ៊ូ សាទីម "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៤៧ឆ្នាំ ជាតិខ្មែរ

មុខរបររកស៊ីលក់ដូរ ទីលំនៅភូមិលេខ៥ ឃុំ.ស្រុក.ខេត្តស្វាយរៀង ។ ឪពុកឈ្មោះអ៊ូ វិន "ស្លាប់" ម្តាយឈ្មោះ ទាំ ញាណ "ស្លាប់" ប្តីឈ្មោះ ខាត់ ធួន "ស្លាប់" ។

- ផ្ទេរសិទ្ធិអោយលោក គីម ចន្ថា អាយុ៤៦ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិលេខ៥ ឃុំស្រុក- ខេត្តស្វាយរៀង ។

- មានមេធាវីលោក ស៊ឹម ស៊ីថាន

**កម្មវត្ថុបណ្តឹង** : ប្តឹងសុំអោយរុះរើផ្ទះចេញពីដីភូមិ និង ជម្ងឺចិត្ត២០ម៉ឺនរៀល ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ១៥៩ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០របស់ឈ្មោះ ណេប សាម៉ាន់ ប្តឹងមិនសុខចិត្ត និង សាលដីការដ្ឋប្បវេណីលេខ៣៩"ក" ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៧៣ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០០របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៩៤ របស់ដើមចោទឈ្មោះ ណេប សាម៉ាន់ ប្តឹងសុំអោយឈ្មោះ អ៊ូ សាទីម រុះរើផ្ទះចេញពីដីភូមិរបស់ខ្លួន ដោយអាងហេតុថា : ដីនេះនៅឆ្នាំ ១៩៨៤ ខ្លួនបានទិញពីឈ្មោះ ប្រាជ សុខា .ប្រាជ សារុធ និង ប្រាជ សារី ហើយពេលដែលខ្លួនទិញនោះម្ចាស់ដី និង រដ្ឋអំណាចបានប្រាប់ដល់ឈ្មោះ អ៊ូ សាទីម អោយរុះរើចេញ ហើយទៅសង់ជាប់ចិញ្ចើមថ្នល់ តែឈ្មោះនេះ សំណូមពរសុំស្នាក់នៅបណ្តោះអាសន្ន ទំរាំរកកន្លែង បានទើបរុះរើ។ មកដល់សព្វថ្ងៃនេះឈ្មោះនេះ នៅតែពុំព្រមរុះរើចេញ ហើយថែមទាំងសង់ផ្ទះរាគទីថែមទៀត ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៣១ ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ១៩៩៥ របស់តុលាការខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ឈ្មោះ ណេប សាម៉ាន់ ទុកជាត្រឹមត្រូវតាម ទំរង់ និង គតិច្បាប់ ។

២-ប្រគល់ដីកើតហេតុ ដែលស្ថិតនៅភូមិទី៥ ឃុំស្វាយរៀង ស្រុកស្វាយរៀង ខេត្តស្វាយរៀង ទទឹង៩.៦០ម បណ្តោយ១១.៦០ម មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ ណេប-សាម៉ាន់ ខាងត្បូងទល់នឹងថ្នល់កៅស៊ូ ខាងកើតទល់នឹងឈ្មោះ សែន ដារ៉ា ខាងលិចទល់នឹងឈ្មោះ គីម ចន្ថា អោយទៅឈ្មោះ ណេប សាម៉ាន់ កាន់កាប់ជាកម្មសិទ្ធិ ចាប់តាំងពីថ្ងៃនេះតទៅ ។

៣-អោយនារីអ៊ូ សាទីម (ចុងចម្លើយ) រុះរើផ្ទះចេញពីដីកើតហេតុដូចមានក្នុងប្រការ២ ខាងលើក្នុងរយៈពេល០១ខែគិតចាប់ថ្ងៃនេះតទៅ ។

៤-អោយនារីអ៊ូ សាទីម បង់ប្រាក់ជំងឺចិត្តទៅអោយឈ្មោះ ណេប សាម៉ាន់ ចំនួន ១៥០.០០០រៀល គ្រប់ចំនួនតែម្តង ចាប់ពីថ្ងៃនេះតទៅ ។ សំណើរលើសពីនេះត្រូវលើកចោល ។

៥-អោយនារីអ៊ូ សាទីម បង់ប្រាក់ប្រដាប់ក្តី សរុប៧.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់៧.០០០រៀល ដែលដើមចោទបានបង់ទុករួចហើយ ។ ប្រាក់នៅសល់ពីការចំណាយគ្មាន។ កាលបើហួសឧទ្ធរណ៍ ត្រូវអោយឈ្មោះនេះ សងប្រាក់៧.០០០រៀលនេះ ទៅដើមចោទវិញ ។

តាមបញ្ញត្តិមាត្រា៥ ,៧ ,៨ ,១០ នៃច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៦-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី។ បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ២ខែគិតចាប់តាំងពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ របស់ឈ្មោះអ៊ូ សាទីម ប្តឹងមិនសុខចិត្ត និង សាលក្រមរដ្ឋប្បវេណីលេខ៣១ ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ១៩៩៥ របស់តុលាការខេត្តស្វាយរៀង ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤២៧ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះអ៊ូ សាទីម ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៣១ ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ១៩៩៥របស់តុលាការខេត្តស្វាយរៀងចោលជាអាសារបង់ ។

៣-ទទួលពាក្យបណ្តឹងរបស់ឈ្មោះ ណោប សាម៉ាន់ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៩៤ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់តែលើកចោលដោយផ្ទុយ នឹង គតិច្បាប់ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីចំនួន ១៣.០០០រៀលដែលឈ្មោះ អ៊ូ សាទីម បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្លីង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ៥.០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ៥.០០០រៀល សរុប ១៣.០០០រៀល តែបង្គាប់អោយឈ្មោះ ណោប សាម៉ាន់ សងប្រាក់នេះទៅអោយដើមបណ្តឹងឧទ្ធរណ៍វិញ ពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៥-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៥៩ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ របស់ឈ្មោះ ណោប-សាម៉ាន់ ប្តឹងមិនសុខចិត្ត និង សាលដីការដ្ឋប្បវេណីលេខ៤២៧ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២១២ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៦ របស់តុលា-ការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងសាទុក្ខលេខ២៥៩ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ របស់ឈ្មោះ ណោប សាម៉ាន់ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៤២៧ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៩៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩៥របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដី ជាន់តុលាការកំពូលចំនួន១៩.០០០រៀល ដែលឈ្មោះ ណោប ម៉ាន់ បានបង់ទុកជាមុនគឺ :

-ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វ៊ីងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០ រៀលសំរាប់ជារង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតំរូវអោយឈ្មោះ អ៊ូ សាទីម សងប្រាក់ចំនួន១៩.០០០រៀល ទៅអោយឈ្មោះណោប សាម៉ាន់ វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២០ ខែសីហា ឆ្នាំ ១៩៩៦ ។

បានឃើញសាលដីការបៀបលេខ៨១B ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ចាត់ភ្នាក់ងារសុរិយោដីខេត្តស្វាយរៀង អោយចុះទៅពិនិត្យ វាស់វែងចំពោះមុខ គូក្ដីឈ្មោះណោប សាម៉ាន់ ដើមចោទ និង ឈ្មោះ គីម ចន្ថា ,នាង ប៊ុន ,អ៊ូ សាទីម ចុងចម្លើយ គូសផែនទី និង ធ្វើសេចក្ដីបញ្ជាក់ថា ទីតាំងទំនាស់មានទំហំប៉ុន្មាន? ព្រំប្រទល់ទល់អ្នកណាខ្លះ? តំលៃដី ទំនាស់ប៉ាន់ស្មានប្រហែលប៉ុន្មាន? ហើយជាពិសេសទីតាំងទំនាស់មានប៉ះពាល់ទៅលើដីរបស់ ឈ្មោះ ណោប សាម៉ាន់ ដែលខេត្តបានចេញសេចក្ដីសំរេចលេខ២០០ស.ស.រ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩១ អោយនោះដែរឬទេ ?

២-ចាត់ចៅក្រមជំនុំជំរះអោយចុះទៅពិនិត្យដល់ទីកន្លែងក្នុងករណីចាំបាច់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣៩"ក" ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០របស់សាលា ឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-សម្រេចទទួលជំនុំជំរះរឿងក្ដីនេះឡើងវិញ តាមអំណាចសាលដីកាលេខ២១២ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៦ របស់តុលាការកំពូល ។

២-ប្រគល់ទីតាំងទំនាស់ដែលស្ថិតនៅភូមិទី៥ ឃុំ.ស្រុក.ខេត្តស្វាយរៀង មានទទឹង ៩,៦០ម បណ្តោយ១១,៦០ម មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះ ណោប សាម៉ាន់ ខាងត្បូងទល់នឹងថ្នល់កៅស៊ូ ខាងកើតទល់នឹងឈ្មោះសែន ដារ៉ា ខាងលិចទល់នឹងគឹម ចន្ថា នេះអោយទៅឈ្មោះ អ៊ូ សាទីម កាន់កាប់ជាកម្មសិទ្ធិ ចាប់តាំងពីសាលដីកាចូលជាស្ថាពរ ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជី៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល និង អាជ្ញាធរតុលាការ៥.០០០រៀល សរុបចំនួន ១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ១៥៩ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០របស់ឈ្មោះ ណោប សាម៉ាន់ ប្តឹងមិនសុខចិត្ត និង សាលដីការដ្ឋប្បវេណីលេខ៣៥"ក" ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះណោប សាម៉ាន់។

បានឃើញសារណាតប ចុះថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០០០ របស់ឈ្មោះ អ៊ូ សាទីម ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-តំណាងមហាអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា : រឿងនេះជារឿងវិវាទដីធ្លី សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

- បានស្តាប់ចម្លើយ របស់ឈ្មោះ ណោប សាម៉ាន់ "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលសវនាការថា : ដីរបស់ខ្លួនមានប័ណ្ណកម្មសិទ្ធិ២២មគុណ២៧ម ដីទំនាស់នេះខ្លួនទិញតាំងពីឆ្នាំ១៩៨២ តូបដែលនាង ប៊ុន ,អ៊ូ សាទីម សង់នៅលើដីនេះ ខ្លួនបានប្តឹងតាំងពីឆ្នាំ១៩៨៤-១៩៨៥ ហើយខ្លួនបានធ្វើពាក្យសុំកាន់កាប់ទំហំ ២២មគុណ២៧ម គឺខ្លួនប្តឹងជាប់រហូតមក ហើយលោកគឹម ចន្ថា ទើបតែទិញ ពីឆ្នាំ១៩៩២ ទេ ។

- បានស្តាប់ចម្លើយ របស់ឈ្មោះ គឹម ចន្ថា "ជាចុងបណ្តឹងសាទុក្ខ" នៅពេលសវនាការថា : ខ្លួនសូមជំរាបប្រធានតុលាការ អំពីដីទំនាស់ជាមួយលោក ណោប សាម៉ាន់ និង ប្រជាជនទាំងបីគ្រួសារ បានវិលពីរបបប៉ុលពតទៅត្រួសត្រាយកាន់កាប់ដីមួយកន្លែង ហើយការកាន់កាប់នោះមានរដ្ឋអំណាចទទួលស្គាល់ ហើយប័ណ្ណកម្មសិទ្ធិទាំងបីគ្រួសារមិនទាក់ទិនទៅនឹងដីឡូត៍របស់ ណោប សាម៉ាន់ ទេ ។

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក ស៊ឹម ស៊ីថាន នៅពេលជំនុំជំរះថា : ខ្លួនសូមឯកភាពរក្សា តម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ដោយសាលាឧទ្ធរណ៍បានចុះស៊ើបអង្កេតដល់

កន្លែងកើតហេតុហើយ ។ តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ២០០៣ កូនក្តីខ្លួនបានដាំដុះមានផ្ទះសម្បែងដូចប្រជាពលរដ្ឋទូទៅ រស់នៅអស់រយៈពេលជាយូរមកហើយ ហើយមានកាតព្វកិច្ច ឥតព្រលាំ និងមានពាក្យកាន់កាប់មានសាក្សីដឹងឮទៀតផង ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីចុងចម្លើយ ។

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**<u>ឧទ្ទេសកាលកំខុស</u>**

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ១៥៩ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០របស់លោកណេប សាម៉ាន់ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ ដល់អង្គសេចក្តីបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការរៀបចំ និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអនុភាពផងដែរ ក្នុងរឿងរដ្ឋប្បវេណី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំនាស់ទំហំ១១,៦០មគុណ៩,៦០ម ស្ថិតនៅភូមិទី៥ ឃុំ.ស្រុក ខេត្តស្វាយរៀង អោយទៅឈ្មោះអ៊ូ សាទីម កាន់កាប់ជាកម្មសិទ្ធិ ដោយអាងហេតុថា អ្នកស្រីអ៊ូ សាទីម មានប័ណ្ណគ្រួសារ និង ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីមុនសេចក្តីសំរេចលេខ២០០ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩១ របស់គណៈកម្មាធិការខេត្តនោះ គឺជាការភ័ន្ត-ច្រឡំ ពីព្រោះថា តាមសេចក្តីសំរេចលេខ២០០ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩១ របស់អាជ្ញាធរខេត្តស្វាយរៀង ពាក្យសុំកាន់កាប់ដី និង ប័ណ្ណសំគាល់សិទ្ធិលេខ$A_1$ ១៦៩៣ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៤ របស់លោក ណេប សាម៉ាន់ បញ្ជាក់ថាដីលោកណេប សាម៉ាន់ មានទំហំ៣៤៥,៦ម$^2$ = ២៧មគុណ១២,៨០ម ។ ចុងចម្លើយមិនបានប្តឹងសុំបដិសេធសេចក្តីសំរេច និងប័ណ្ណសំគាល់សិទ្ធកាន់កាប់ប្រើប្រាស់ដីធ្លីខាងលើទេ ។ ការសំរេចដូច្នេះនាំឱ្យប៉ះពាល់ដល់ដីរបស់ដើមចោទ១ចំណែក ។

- យល់ឃើញថា ចុងចម្លើយពុំបានប្តឹងសុំមោឃៈភាពសេចក្តីសំរេចលេខ២០០ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩១ របស់អាជ្ញាធរខេត្តស្វាយរៀង និង ប័ណ្ណសំគាល់សិទ្ធិលេខ $A_1$១៦៩៣ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៤ ទេ ហើយនាពេលសវនាការនេះចុងចម្លើយក៏បានឆ្លើយទទួលស្គាល់ថា សេចក្តីសំរេច និង ប័ណ្ណខាងលើពុំប៉ះពាល់ដីរបស់ខ្លួនទេ ដូច្នេះតុលាការកំពូលគប្បីតម្កល់សេចក្តីសំរេច និង ប័ណ្ណសំគាល់សិទ្ធិខាងលើជាបានការ ។

- យល់ឃើញថា ការដែលលោកណេប សាម៉ាន់ ទាមទារយកដីទំនាស់ពីអ្នកស្រីអ៊ូ សាទីម

ទំហំ១១,៦០មគុណ៩,៦០ម ដោយផ្អែកតាមលិខិតផ្ទេរផ្ទះ និង ដីចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៤ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា តាមពាក្យសុំកាន់កាប់ដី តាមប័ណ្ណសំគាល់សិទ្ធដី ,តាមកំណត់ហេតុចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៩៤ និងសេចក្តីសំរេចលេខ២០០ស.ស.រចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩១ របស់គណៈកម្មាធិការប្រជាជនខេត្តស្វាយរៀង ដីរបស់លោកមានទំហំតែ២៧មគុណ១២,៨០ម ប៉ុណ្ណោះ។ ដូច្នេះដីទំនាស់រវាងអ្នកស្រី អ៊ួ សាទីម ជាមួយលោកមានទំហំ៧,៤មគុណ៩,៦០មប៉ុណ្ណោះ

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៣៩"ក"ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យ សេចក្តីទំនោះមុខក្តី**

១- ទទួលបណ្តឹងសាទុក្ខលើកទី២លេខ១៥៩ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០ របស់លោក ណោប សាម៉ាន់ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ៣៩ "ក" ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣- ទទួលស្គាល់សេចក្តីសំរេចលេខ២០០ស.ស.រ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩១របស់ខេត្តស្វាយរៀង និង ប័ណ្ណសំគាល់សិទ្ធិលេខ $A_1$១៦៩៣ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៤ របស់លោក ណោប សាម៉ាន់ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤- ប្រគល់ដីទំនាស់ទំហំ៧,៤០មគុណ៩,៦០ម ស្ថិតនៅភូមិទី៥ ឃុំស្វាយរៀង ស្រុកស្វាយរៀង ខេត្តស្វាយរៀង មានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះណោប សាម៉ាន់ ខាងត្បូងទល់នឹងឈ្មោះ អ៊ួ សាទីម ខាងកើតទល់នឹងឈ្មោះ សែន ដារ៉ា ខាងលិចទល់នឹងឈ្មោះគីម ចន្ថា អោយទៅឈ្មោះ ណោប សាម៉ាន់ កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៥-បង្គាប់អោយអ្នកស្រី អ៊ួ សាទីម រុះរើផ្ទះចេញពីដីកើតហេតុទំហំ៧,៤០មគុណ៩,៦០ម ។

៦- ប្រគល់ដីទំហំ៩,៥០មគុណ៩,២០ម ដែលមានព្រំប្រទល់ខាងជើងទល់ ណោប សាម៉ាន់ ខាងត្បូងទល់ថ្នល់កៅស៊ូ ខាងកើតទល់ សែន ដារ៉ា ខាងលិចទល់ឈ្មោះគីម ចន្ថា ឱ្យឈ្មោះ អ៊ួ-សាទីម កាន់កាប់គ្រប់គ្រងតទៅ ។

៧- រំលែកប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោក ណោប សាម៉ាន់ បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀលសម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៨- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែមិនា ឆ្នាំ២០០៣។